www.khmerpostusa.com
សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA


Soben Pin
Co-Founder & Publisher

Free Copies
Vol. 13. Issue #290
March 09, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

ក្រសួងសុខាភិបាលចេញសេចក្ដីប្រកាស ផ្លូវការស្ដីពីការរកឃើញវីរុស Covid-19

សូមអាននៅទំព័រទី ០៣



-វគ្គសិក្សារដូវក្ដៅឆ្នាំនេះសម្រាប់កុមារ...
-Keep Kids & Teens Busy This Summer

សូមអាននៅទំព័រទី ០៨/០៩



ទិវានៃការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅក្រុងឡូវែល នៅថ្ងៃអង្គារ ទី១០ ខែមិនា

សូមអាននៅទំព័រទី ០៥

Lowell Health Department
Prevent • Promote • Protect

កើ្តមរតកព្រះតេជគុណ សៅ ឃន ចេញជា...

សូមអាននៅទំព័រទី ១០



# ទស្សនៈកិច្ចរបស់ ប៉ាទ្រីក ម័រហ្វី នៅឡូវែល

ដោយៈ ពិន សំខុន

លោកឯកអគ្គរដ្ឋទូតអាមេរិកាំងប្រចាំកម្ពុជា ប៉ាទ្រីក ម័រហ្វី បានមកដល់ទីក្រុងឡូវែល ដ៏សម្បូរប្រជាពលរដ្ឋខ្មែររស់នៅ កាលពីថ្ងៃចន្ទ ទី២ នឹងថ្ងៃអង្គារទី៣ មិនា កន្លងទៅ។ លោកមកទីនេះ តាមសេចក្ដីអញ្ជើញរបស់លោក សុខារី ចៅ សមាជិកថ្មី នៃក្រុមប្រឹក្សាក្រុងឡូវែល នឹងលោក ខេរិន ខបលីន អតីតទីប្រឹក្សាសាលាក្រុងដដែល **តទៅទំព័រទី ០៨**



លោកឯកអគ្គរដ្ឋទូត ប៉ាទ្រីក ម័រហ្វី អញ្ជើញទៅជួបក្រុមនិស្សិតនៅមហាវិទ្យាល័យ MCC



លោកឯកអគ្គរដ្ឋទូត ប៉ាទ្រីក ម័រហ្វី

# បោះឆ្នោតថ្ងៃ“ស៊ូពែធូស្ដេយ”២០២០




ដោយៈ ពិន សំខុន

បន្ទាប់ពីជជែកដេញដោលជាសាធារណៈក្នុងរង្វង់បេក្ខជនប្រធានាធិបតី ខាងគណបក្សប្រជាធិបតេយ្យអស់រយពេលច្រើនខែ ក្នុងនោះមានបេក្ខស្រីប្រុសប្រមាណជា២០រូប ឥឡូវនៅសល់តែ៤នាក់ខំបញ្ចេញ ថ្វីវោហាសម្រាប់ឃោសនានៅឡើយ។

ថ្ងៃអង្គារទី៣កន្លងទៅនេះ គឺ"ស៊ូពែធូស្ដេយ Super Tuesday" ដែលជាថ្ងៃដ៏សំខាន់សម្រាប់សមាជិក **តទៅទំព័រទី ០២**



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
Excellent Service Since 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ថ្លៃពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.

LAW OFFICE OF LOUIS S. HASKELL
16 PINE STREET
LOWELL, MA
(978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

តមកពីទំព័រទី ០១

# បោះឆ្នោតថ្ងៃ"ស៊ុបពែធូស្ដេយ"....

"គណបក្សប្រជាធិបតេយ្យ" គេចម្រាញ់យកបេក្ខជនតែម្នាក់ ដើម្បីទៅប្រជែងយកឈ្នះលើបេក្ខជន"គណបក្សសាធារណរដ្ឋ", គេធ្វើតេស្តនៅក្នុងរដ្ឋសំខាន់ៗ១៤ នៃសហរដ្ឋអាមេរិកហើយ គេយកឈ្នះគ្នាលើចំនួន"ឌេឡេ គ្គេត" ដែលគេដណ្ដើមបានច្រើនជាងគេ អ្នកនោះនឹងត្រូវបក្សគេតែងតាំងជា"បេក្ខជនរបស់គណបក្សប្រជាធិបតេយ្យ"នៅក្នុងមហាសន្និបាទ។

នៅថ្ងៃពុធទី៤នេះដោយលទ្ធផលមិនទាន់ចប់សព្វគ្រប់ គេនៅឃើញផ្សាយបេក្ខជន៤រូបនៅឡើយ ដែលមានលោកអតីតអនុប្រធានាធិបតី ជោ បាយដិនដឹកមុខគេ, នៅលំដាប់បន្ទាប់មកលោកព្រឹទ្ធសមាជិក បើនី សេនឌើ, អ្នកទី៣ គឺអតីតអភិបាលក្រុងញូយ៉ក ម៉ាយកិល ប្លូមបើក ដែលទើបនឹងប្រកាសដកបេក្ខភាព ហើយផ្ទេរការគាំទ្រទៅឱ្យ ជោ បាយដឹន រួចទៅហើយនាព្រឹកទី៤នេះ, នៅសល់តែលោកស្រី អេលីសាបេទ វ៉ររ៉េន ដែលជាសម្លេងទី៤ មិនទាន់ប្រកាសថា យ៉ាងណានៅឡើយទេ។

លោក ប៉ែនី សែនឌើ នៅមានសង្ឃឹមនៅឡើយ ថានឹងបានក្លាយជាបេក្ខជនប្រធានាធិបតី តែលោកអតីតអនុប្រធានាធិបតី ជោ បាយដិន ទើបនឹងទទួលជ័យលាភីកាលពីថ្ងៃ"ស៊ូពែធូស្ដេយ"យ៉ាងគាប់ចិត្ត បាន"ឌេឡេគ្គេត"៥៦៦ ស៊ីដាច់លើស សែនឌើ ដែលបានតែ៥០១។ លោក ប្លូមបើក ជាកំពូលមហាសេដ្ឋីម្នាក់ ដែលចូលប្រឡូកក្រោយគេ មិនមានសង្ឃឹមច្រើនទេ ដូចគ្នានឹង អេលីសាបេត វ៉ររ៉េន ដែរ ណារដ្ឋម៉ាសាឈូសិត បាន"ដេឡេគ្គេត" ត្រឹមតែតិចជាង ១០០ លែងមានវាសនាតាមទាន់ អ្នកទាំង២ ដែលបានដឹកមុខនោះឡើយ។

គេក៏នៅឆ្ងល់នៅឡើយថា ហេតុអ្វីបានថ្ងៃនេះទៅហើយ បានជាគណបក្សប្រជាធិបតេយ្យមិនទាន់បានបេក្ខជននៅឡើយ? តើសម្លេង "ដេឡេគ្គេត" របស់អ្នកបោះបង់ការប្រកួតនឹងក្លាយទៅជាយ៉ាងណា?

លោក វ៉ាសនា នួន សមាជិកក្រុមប្រឹក្សាក្រុងឡូវែល ខាងគណបក្សប្រជាធិបតេយ្យនិយាយប្រាប់ខ្មែរផុសថា "បេក្ខជនឈ្នះគេ ហើយពិន្ទុនៅគៀកគ្នា ពុំអាចធ្វើសេចក្ដីសម្រេចនៅពេលនេះបានទេ គេត្រូវបន្ដរកលទ្ធផលពិតំបន់ផ្សេងៗទៀតមកបន្ថែម រហូតដល់ថ្ងៃសន្និបាទ Convention ទើបគេសម្រេចថា នឹងយកបេក្ខជន "គណបក្សប្រជាធិបតេយ្យតែម្នាក់យកទៅប្រកួតនឹង ឌុណល ត្រាំ ជាប្រធានាធិបតីផង នឹង ជាសមាជិក"គណបក្សសាធារណរដ្ឋ"។គឺនៅពេលប្រជុំធ្វើសន្និបាទនោះហើយ ដែលបេក្ខជនដែលបានបោះបង់បេក្ខភាព គេនឹងនាំយកចំនួន "ឌេឡេគ្គេត"របស់គេ មកប្រគល់ឱ្យអ្នកដែលគេគាំទ្រ ដូចជាលោកស្រីព្រឹទ្ធសមាជិក អេមី




ក្លូប៊ូឆា, លោកចៅហ្វាយក្រុង ភីត ប៊ូទីគី,ជាដើម... នៅមានលោកដំណាងរាស្ត្រ បូតូ រួក, លោកតំណាងក្រុមគណបក្សភាគច្រើន ជេម ក្លាយបើន...ដែលនឹងផ្ដល់ការគាំទ្រដល់ ជោ បាយដិន... តែគេមិនទាន់ដឹងច្បាស់ថា លោកស្រីព្រឹទ្ធសមាជិក អេលីសាបេត វ៉ររ៉េន នឹងទៅគាំទ្រនរណានៅឡើយទេ ប៉ុន្តែ"ស៊ូពែធូស្ដេយ"លើកនេះ បានធ្វើឱ្យ លោកស្រី វ៉ររ៉េន ខកចិត្តយ៉ាងខ្លាំង ដោយលោកស្រី ធ្លាប់មានសង្ឃឹមយ៉ាងមាំថា លោកស្រីនឹងមានសមត្ថភាពអាចទៅដល់Convention បានតែលទ្ធផលបែរជាធ្លាក់ចុះទៅវិញ។

លោកមហាសេដ្ឋីអតីតចៅហ្វាយក្រុងញូយ៉ក ប្លូមបើក (មានលុយច្រើនជាង ឌុណល ត្រាំ ទៅទៀត) បានចំណាយប្រាក់៥០០លានសម្រាប់ឃោសនា តែបានលទ្ធផលលំដាប់ថ្នាក់លេខ៣ ដែរ ក៏គាំទ្រ ជោ បាយដិន ទៅហើយដែរ។ ប៉ុន្តែនៅសល់វរជនដ៏សំខាន់ម្នាក់ទៀត ដែលគេរង់ចាំនោះ គឺលោកអតីតប្រធានាធិបតី បារ៉ាក់ អូបាម៉ា ដែលគេសង្ស័យថានឹងមកគាំទ្រអនុប្រធានាធិបតីរបស់លោកតែមិនទាន់បង្ហាញមុខព្រួញរបស់លោកនៅឡើយទេ។

លោកប្រធានាធិបតី ត្រាំ នៅក្នុងភាពរង់ចាំគួរប្រកួត បានជួយជម្រុញឱ្យ សែនឌើ មានប្រៀបលើ បាយដិន ប៉ុន្តែ សែនឌើ បានយល់ការក៏ទាត់ចោលការជួយជម្រុញ ពីសំណាក់ ឌុណល ត្រាំ ភ្លាមដែរ។




# ក្រសួងសុខាភិបាលចេញសេចក្តីប្រកាសផ្លូវការអំពី “ករណី រកឃើញបុរសជនជាតិខ្មែរម្នាក់ អាយុ៣៨ឆ្នាំ មានផ្ទុកមេរោគ Covid-19 នៅខេត្តសៀមរាប

ភ្នំពេញៈ នៅយប់ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាលចេញសេចក្តីព័ត៌មានប្រកាសផ្លូវការអំពី “ករណីរក



ឃើញបុរសជនជាតិខ្មែរម្នាក់ អាយុ៣៨ឆ្នាំ មានផ្ទុកមេរោគ Covid-19 នៅខេត្តសៀមរាប ។




សេចក្តីប្រកាសព័ត៌មានបានបញ្ជាក់ថា នៅវេលាម៉ោង ១២:៥០នាទី ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០នេះ ក្រសួងសុខាភិបាលទទួលបានលទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាថា បុរសម្នាក់អាយុ៣៨ឆ្នាំ ដែលជាអ្នកប៉ះពាល់ផ្ទាល់ជាមួយបុរសជនជាតិជប៉ុន អាយុជាង៤០ឆ្នាំ មានវិរុសកូវីដ១៩នោះ មានលទ្ធផលវិជ្ជមានវីរុសកូវីដ១៩ ។ (ព័ត៌មានលម្អិតសូមអានសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល) ។

ពាក់ព័ន្ធនឹងករណីរកឃើញមនុស្សផ្ទុកមេរោគ Covid-19 សម្តេចតេជោ ហ៊ុន សែន បានបញ្ជាឱ្យបិទសាលារៀននៅទីរួមខេត្តសៀមរាបជាបណ្តោះអាសន្ន ព្រមទាំងបិទការប្រារព្ធព្រឹត្តិការអង្គរសង្ក្រាន្តនៅខេត្តសៀមរាបផង ។ នេះបើ យោងតាមការបញ្ជាក់របស់លោករដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅក្នុងសន្និសីទសារព័ត៌មានមួយនៅទីស្តីការក្រសួងសុខាភិបាល នាព្រលប់ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០២០នេះ ។

វិធានការបិទសាលារៀន និងបិទព្រឹត្តិការអង្គរសង្ក្រាន្តនេះ បានធ្វើឡើងបន្ទាប់ពីកម្ពុជាបានរកឃើញថា ជនជាតិខ្មែរម្នាក់នៅក្នុងខេត្តសៀមរាប បានកើតជំងឺ COVID-19 ដែលឆ្លងពីជនជាតិជប៉ុន ។ Fresh News


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

COMM UNITY TEAM WORK

“កិច្ចប្រជុំក្រុមប្រឹក្សា”

កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា”កុំមូនីធី ទីមវើក” បានត្រូវកំណត់នៅថ្ងៃពុធ ទី២៥ មិនា ២០២០ វេលាល្ងាច ម៉ោង៧គត់

នៅ១៥៥ផ្លូវមើរីម៉ាក ជាន់ទី២ បន្ទប់”ម៉ាជ្ជរី ម៉ាក់ឌឺរម៉ុទ”- សាធារណជនសូមស្វាគមន៍

BOARD MEETING

Community Teamwork monthly board meeting is scheduled on Wednesday, March 25th, 2020 at 155 Merrimack Street. Marjorie McDermott Board Room. 2nd Floor. Lowell, MA 01852. Meetings are called to order promptly at 7:00 P.M. Public is welcome.

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

# ក្លាយខ្លួនជាសហគ្រិននាពេលអនាគតខាងមុខ: យកពេលឈប់សម្រាកនៅខែកុម្ភៈមកសិក្សាថ្នាក់មើលថែទាំកុមារ

ដោយ Caitlin Buckley, MCC Writer

ឡូវែល, ម៉ាសាជូសេតៈ វាមិនដែរឃើតពេលពេកនោះទេសម្រាប់ចាប់ផ្តើមនូវការបើករបរដោយខ្លួនឯងនោះ។ សហគ្រិនវ័យក្មេង "ដែលមានអាយុចាប់ពី១១ឆ្នាំ ទៅ១៥ឆ្នាំ" អាចចំណាយពេលវេលាសប្តាហ៍វិស្សមកាលក្នុងខែកុម្ភៈរបស់ពួកគេជាមួយនិងសាលាមីុឌលស៊ិចខាំញ៉ូនីធី ខលលេច (Middlesex Community College) ដោយធ្វើការសិក្សាដើម្បីទទួលបាននូវលិខិតបញ្ជាក់វគ្គបណ្តុះបណ្តាលមើលការថែទាំកុមារ។ វគ្គសិក្សាប្រាំពីរម៉ោងរយៈពេល២ថ្ងៃ នឹងចាប់ផ្តើមពីម៉ោង ៩ ព្រឹក ដល់ ១២:៣០ ថ្ងៃត្រង់ នៅថ្ងៃអង្គារ ទី១៨ ខែកុម្ភៈ និងថ្ងៃព្រហស្បតិ៍ ទី២០ ខែកុម្ភៈ នេះ។

សិស្សនឹងសិក្សាពីចំណេះដឹង និងជំនាញសំខាន់ៗ ដើម្បីមើលថែទាំកុមារ និងទារកប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ។ សិស្សចូលរួមវគ្គសិក្សានេះ នឹងអភិវឌ្ឍន៍ជំនាញភាពជាអ្នកដឹកនាំ, រៀនពីវិធីក្នុងការបង្កើតអាជីវកម្មមើលថៃកុមារ, មើលថែរក្សាខ្លួនឯង និងអ្នកដ៏ទៃប្រកបដោយសុវត្ថិភាព, ជួយក្មេងៗក្នុងការ



ប្រកាន់អាកប្បកិរិយាឱ្យបានល្អ, និងរៀនពីមូលដ្ឋាននៃការថៃទាំកុមារ និងការសង្គ្រោះបឋម។ អ្នកសិក្សាត្រូវបានស្នើរឱ្យយក នូវកូនតុក្កតាជាមួយខ្លួនពីផ្ទះផងដែរ។

អ្នកនាង Lauren Ellis ដែលជាអ្នកគ្រប់គ្រងកម្មវិធីសិក្សានៃសាលា MCC សម្រាប់កម្មវិធី MILES និង College for Kids & Personal Enrichment បានមានប្រសាសន៍ថា "វាតែងតែមានភាពរំភើបរីករាយក្នុងការរៀនពីជំនាញថ្មី ហើយនៅពេលដែលមានសប្តាហ៍វិស្សមកាលការចុះឈ្មោះសិក្សា គឺជាពេលវេលាដ៏ល្អបំផុតដែលត្រូវធ្វើ"។ អ្នកនាងក៏បានបន្ថែមទៀតថា "ថ្នាក់សិក្សាការថែទាំកុមាររបស់យើងអាចធ្វើការបណ្តុះបណ្តាលយុវជនចំនួន២០នាក់ លើការមើលថែកុមារព្រមទាំងការសង្គ្រោះបឋម, និងការសង្គ្រោះសរសៃចង្វាក់បេះដូង (CPR) វាអាចជួយពួកគេក្នុងការអភិវឌ្ឍន៍ជំនាញដឹកនាំ និងការការសាងក្រុម។ យើងទទួលបានសិស្សដែលមានគំនិតវ័យក្មេង ដែលគិតអំពីយ៉ាងជឹកដល់អំពីការបង្កើតអាជីវកម្ម"។

តំលៃក្នុងការសិក្សា គឺ $១៣០ ដោយមានរួមបញ្ចូលថ្លៃធ្វើលិខិតបញ្ជាក់ការសិក្សា ព្រមទាំងសៀវភៅបណ្តុះបណ្តាលពីការមើលការថែទាំកុមារ, ឯកសារមគ្គុទេសក៏យោងក្នុងការជួយសង្គ្រោះពេលមានអាសន្ន និង CD-ROM សម្រាប់អ្នកមើលថៃក្មេងៗក្នុងការប្រើប្រាស់ក្នុងថ្នាក់ និងពេលបំពេញការងារ។

កន្លែងមានកំណត់ "ចុះឈ្មោះ រឺចង់ដឹងពីព័ត៌មានបន្ថែមអំពីវគ្គសិក្សានេះ រឺកម្មវិធីសិក្សាផ្សេងទៀតដែលផ្តល់ដោយសាលា មីុឌលស៊ិច សូមចូលទៅកាន់វ៉ិបសាយ www.middlesex.mass.edu/careertraining/ រឺទូរស័ព្ទទៅកាន់លេខ1-800-818-3434។






មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

# ទិវានៃការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ នៅក្រុងឡូវែល នៅថ្ងៃអង្គារ ទី១០ ខែមីនា

ដោយខ្មែរផុស ស.រ.អា

ទិវានៃការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ (A free unwanted medication and sharps disposal day) នឹងរៀបចំឡើងនៅថ្ងៃអង្គារ ទី១០ ខែមិនា ឆ្នាំ ២០២០ ចាប់ពីម៉ោង ២:០០ ថ្ងៃត្រង់ ដល់ ៦:០០ ល្ងាច នៅទីតាំងនាយកដ្ឋានសុខាភិបាលក្រុងឡូវែល (the Lowell Health Department) ដែលមានទីតាំងស្ថិតនៅផ្លូវ 314 Pine Street ក្រុងឡូវែល រដ្ឋម៉ាសាជូសេត។ សមាជិកសហគមន៍ទាំងអស់ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកម្មវិធីនេះដោយនាំយកមកជាមួយនូវរបស់របរដែលលែងត្រូវការ ឬ អត់ប្រើប្រាស់ទាក់ទងនឹងសំណល់វេជ្ជសាស្ត្រ ដូច ជាវេជ្ជបញ្ជាថ្នាំដែលលែងត្រូវការ, ថ្នាំដែលទិញ មិនមានវេជ្ជបញ្ជា, ថ្នាំទឹក, បំណែកនៃសំបក ថ្នាំ, បំពុងផ្លុងដង្ហើម, ឧបករណ៍មុតស្រួច (រួមមានសារ៉ូម, កូនកាំបិតតូចៗចាក់ជូសឈាម, បំពង់សម្រាប់ដាក់ឈាមធ្វើតេស, ប៊ិច និង ម្ជុល), និងឧបករណ៍ណារចាន ដែលផុតកំណត់មកកាន់នាយកដ្ឋានសុខាភិបាលក្រុងឡូវែល ដើម្បីបោះចោលឱ្យបានត្រឹមត្រូវ។

ទិវានៃការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ នេះគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់សាលាក្រុងឡូវែលក្នុងគោលបំណងដើម្បីកាត់បន្ថយចំនួនដ៏ខ្ពស់នៃគ្រោះថ្នាក់ដែលទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំ Opioid និងការប្រើប្រាស់វេជ្ជបញ្ជាផ្សេងៗទៀត ដែលកើតឡើងតារយៈការការយកថ្នាំ ឬឧបករណ៍ចេញដែលអាចត្រូវបានប្រើខុសបច្ចេកទេស ឬប្រើបំពាននឹងវេជ្ជបញ្ជាចេញពីផ្ទះរបស់ប្រជាពលរដ្ឋ។ យោងតាមអង្គការ Partnership for Drug-Free Kids បានឱ្យដឹងថា មួយភាគបីនៃយុវជន និងយុវវ័យដែលរកឃើញប្រើប្រស់ថ្នាំ ឬឧបករណ៍ពេទ្យផ្សេងខុសពីវេជ្ជបញ្ជា គឺបានមកពីមិត្តភ័ក្រ្ត, គ្រួសារ និងអ្នកស្គាល់គ្នា។

ក្នុងឆ្នាំ ២០១៩ ថ្នាំ ឬឧបករណ៍វេជ្ជសាស្ត្រដែលមិនត្រូវការមានចំនួនសរុប ៤៧០ ផោន និងឧបករណ៍មុតស្រួចមានចំនួនសរុប៧១៩ផោនត្រូវបានយកចេញពីសហគមន៍របស់យើងតាមរយៈទិវានៃការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រត្រីមាសទី៤ របស់នាយកដ្ឋានសុខាភិបាលក្រុងឡូវែល។ដោយមានការសហការណ៍ដៃគូរជាមួយនឹងការិយាល័យប៉ូលីសក្រុងឡូវែល ថ្នាំ ឬឧបករណ៍វេជ្ជសាស្ត្រ និងឧបករណ៍មុតស្រួចដែលពលរដ្ឋនៅក្នុងសហគមន៍របស់យើងយកមកនៅក្នុងកំឡុងពេលនៃទិវានេះ ត្រូវបានបោះចោលដោយសុវត្ថិភាព ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់សហគមន៍ និងបរិដ្ឋាន។

Lowell Health Department
Prevent • Promote • Protect

# Lowell's Unwanted Medication & Sharps Disposal Day is Tuesday, March 10

By KhmerPost USA

A free unwanted medication and sharps disposal day is on Tuesday, March 10th, 2020 from 2:00 pm – 6:00 pm at the Lowell Health Department, 314 Pine Street, Lowell, MA. Community members are invited to bring their unwanted prescription and over-the-counter medications, liquid medications, prescription patches, inhalers, sharps (including syringes, lancets, EpiPens, and pen and pump needles), and expired Narcan to the Lowell Health Department be disposed of properly.

The Unwanted Medication and Sharps Disposal Day is part of the City of Lowell's efforts to reduce the high number of opioid and other prescription medication-related incidents that occur by removing medications, which could be misused or abused, from residents' homes. According to the Partnership for Drug-Free Kids, two-thirds of teens and young adults who report abuse of prescription medications are getting it from friends, family, and acquaintances.




In 2019, a total of 470 pounds of unwanted medications and 719 pounds of sharps were removed from the community through the Lowell Health Department's four quarterly Unwanted Medication and Sharps Disposal Day events. In partnership with the Lowell Police Department, medication and sharps that are brought in by community members during Disposal Day events are disposed of safely to reduce harm to the community and the environment.

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្ទេត
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
Residential Leasing Center

ដាញ៉េល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនស្ទូរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business

508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com

# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត មុី សុខារិទ្ធ, M.D.
**Sokharith Mey, M.D.**

លោក ចាន់ ទូច , C.N.P.
**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
**Now Accepting New Patients**

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហ៊េល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

# ប្រម៉ោយដំរី ជាដើម ឱសថខ្មែរយើងដ៏អស្ចារ្យ!



ប្រម៉ោយដំរី ជាដើមឱសថខ្មែរយើងដ៏អស្ចារ្យជួយព្យាបាលម្ចឹល្អិតល្ហៃ អ្នកមិនឃ្លានបាយបញ្ហាក្រពះពោះវៀន ជួយអ្នកស្គមឱ្យឡើងគីឡូរម្ងាប់ប្រទាលត្រអាកកាត់បន្ថយកំដៅក្នុងខ្លួន បង្ក្រាបពិសបូសធំៗ

*** ព្យាបាលៈ**

កបចំពោះអ្នកមិនឃ្លានបាយ ខ្សោយ ល្អិតល្ហៃ ជម្ងឺរុំារ៉ៃទាស់ មិនដឹងមុខ គេងមិនសូវបាន រដូវមកមិនទៀង បញ្ហាក្រពះ ឬពោះវៀន។

*** វិធីប្រើៈ**

១-ប្រើដើម និងស្លឹក លាងឱ្យស្អាត បុកពូតយកទឹក (ត្រងយកកាកចេញ) ញ៉ាំបរិមាណ ស្លាបព្រាបាយ មុនហូបអាហារ ១៥នាទី (ហាមប្រើលើស)។

២-ដាក់ហាលដើម និងស្លឹកហាលក្នុងម្លប់ឱ្យស្ងួត ប្រមាណ ១៥ក្រាម ដាំទឹកហូប កន្លះកែវតូចមុនបាយ។

**-រម្ងាប់ប្រទាលត្រអាកៈ** ឆ្អុងស្លឹក និងមែកខ្ចីៗហាលក្នុងម្លប់ឱ្យស្ងួត ផឹកដើម្បីរម្ងាប់ប្រទាលត្រអាក ក្រហាយស្បែក។

**ជំនួយឱ្យធាត់ៈ** ញ៉ាំ១ថ្ងៃជាង២លីត្រនឹងជំនួយឱ្យឆាប់មានសាច់។

**-បង្ក្រាបបូសធំៗៈ** យកបី ឬបួនដើមមកបុកលាយនឹងពងមាន់ស្រែយកអាក្រហមចេញភក់ៗរួចបិតចំពីលើបូស១ថ្ងៃ៤-៥ដងវានឹងរលាយទៅវិញបាត់ឈឺ។

ហាលអោយស្ងួតកិនជាម្សៅ ក៏រិតពី ៣-៦ងម ឬស្ងោរផឹកជាទឹក២០០-៤០០មល សំរាប់ព្យាបាលជំងឺរលាកតំរងនោម។

*ហើមសើរស្បែក ដំនិងបិទ កន្លែងហើម ហាមប្រើចំពោះអ្នកជំងឺរលាកថ្លើម។

***ប្រយ័ត្នៈ** សូមកុំប្រើជាមួយថ្នាំពេទ្យ ហាមស្ត្រីមានផ្ទៃពោះប្រើ។ បើកម្លាំងខ្សោយពេកប ន្ថយបរិមាណប្រើឱ្យតិច ព្រោះប្រើច្រើនពេកអាចមានអាការៈពុលក្អួតបាន។




KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



អគ្គនាយក សុបិន្ត ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com



Richard Howe Jr.
Contributed Writer | Editor

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com
ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA





# វគ្គសិក្សារដូវក្តៅឆ្នាំនេះសម្រាប់កុមារ និងយុវជនជាមួយ នឹងសាលាមីឌុលស៊ិច ខំញូនីធី ខលលិច

ឡូវែល,បេដហ្វត, ម៉ាសាជូសេត” សម្រាប់រដូវក្តៅខាងមុខនេះ សាលាមីឌុលស៊ិច ខំញូនីធី ខលលិច បានរៀបចំកម្មវិធីសិក្សាពិសេសទាក់ទងនឹងការពង្រីកចំណេះដឹងផ្នែកអេលិចត្រូនិច, វិទ្យាសាស្ត្រ, ពិសោធន៍, ការអភិវឌ្ឍន៍គំនិត, វេជ្ជសាស្ត្រ និងមុខវិជ្ជាជាច្រើនទៀតសម្រាប់កុមារ និងយុវជនដែលមានអាយុចាប់ពី៨ឆ្នាំ រហូតដល់ ១៧ឆ្នាំ។ កម្មវិធីសិក្សានេះ មានរយៈពេលចំនួនប្រាំមួយសប្តាហ៍ចាប់ផ្តើមពីថ្ងៃទី៦ ខែកក្កដា រហូតដល់ថ្ងៃទី១៣ ខែសីហា ដោយមានថ្នាក់ពេញម៉ោង និងថ្នាក់កន្លះថ្ងៃ នៅទីតាំងឡូវែល និងបេដហ្វតរបស់សាលាមីឌុលស៊ិច ។

ថ្នាក់ពេញម៉ោង គឺចាប់ផ្តើមពីម៉ោង ៨:៣០ ព្រឹក ដល់ម៉ោង ៤:៣០ រសៀល ពីថ្ងៃច័ន្ទរហូតដល់ថ្ងៃព្រហស្បតិ៍។ ចំណែកថ្នាក់សិក្សាកន្លះថ្ងៃវិញ គឺពីម៉ោង ៨:៣០ ព្រឹកដល់ថ្ងៃត្រង់ ហើយពីម៉ោង១ថ្ងៃត្រង់ ទៅ ៤:៣០ រសៀល។ សម្រាប់សិស្សដែលចុះឈ្មោះចូលរៀនថ្នាក់សិក្សាកន្លះថ្ងៃ អាចនៅបរិវេណសាលារៀនសម្រាប់ស្រស់ស្រូបអាហារថ្ងៃត្រង់ក្នុងចន្លោះម៉ោងសិក្សា។



កម្មវិធីសិក្សារដូវក្តៅដែលបែបរីករាយ និងលក្ខណៈជាការចូលរួមនេះ ឱ្យដល់កុមារ និងយុវជនមានឱកាសក្នុងការស្វែងរកនូវអាជីព, សិក្សានូវជំនាញថ្មី, ជួបជាមួយនឹងមិត្តភក្ត្រថ្មី និងជំរុញភាពជឿជាក់លើខ្លួនឯង។លោកគ្រូអ្នកគ្រូមកពីសាលារដ្ឋ ឬអ្នកមានទេពកោសល្យដែលជាអ្នកជំនាញនឹងទទួលខុសត្រូវក្នុងការបង្រៀនសម្រាប់កម្មវិធីសិក្សានេះ។

លោក ឡូរេន អេលីស (Lauren Ellis) ដែលជាអ្នកគ្រប់គ្រងកម្មវិធីសិស្សផ្នែក MILES, College for Kids & Personal Enrichment បានមានប្រសាសន៍ថា “ការសិក្សានៅមហាវិទ្យាល័យ គឺវាថ្លៃខ្លាំងណាស់ តែនៅពេលដែលអ្វីៗត្រូវបានបញ្ចប់ទៅនោះ វាគឺជាបទពិសោធន៍ដ៏ល្អបំផុតសម្រាប់អ្នកដែលបានឆ្លងកាត់វានោះ”។ លោកបានទៀតបន្ថែមថា “ខ្ញុំចង់បង្ហាញឱ្យឃើញថា កម្មវិធី College for Kids program គឺវាដូចទៅនឹងកម្មវិធីនៅមហាវិទ្យាល័យដូច្នេះដែរ។ កម្មវិធី College for Kids program មានរយៈពេលប្រាំមួយសប្តាហ៍នៃការសិក្សាមិនចេះចប់នៅក្នុងបរិបទសប្បាយរីករាយ, ការជួយគ្នា និងការពង្រឹងចំណេះដឹង”។ ដូច្នេះបើលោកអ្នកចង់ដឹងពីវគ្គសិក្សារដូវក្តៅនិងការចុះឈ្មោះសិក្សាឆ្នាំ២០២០ របស់សាលាមីឌុលស៊ិច ខំញូនីធីខលលិច លោកអ្នកអាចចូលទៅកាន់វិបសាយរបស់សាលារៀនផ្ទាល់តាមរយៈ www.middlesex.mass.edu/collegeforkids / វិទ្យុស័ព្ទ ៧៨១-២៨០-៣៦៦៣

DAN O'BRIEN
DAN O'BRIEN

សូមស្វាគមន៍ និងសូមមកកាន់ភ្នាក់ងារលក់ ដើម្បីទិញរថយន្តថ្មីរបស់អ្នកនៅថ្ងៃនេះ! យើងមានការបញ្ចុះតម្លៃរាប់រយគ្រឿងនៃរថយន្តថ្មី និងរថយន្តប្រើប្រាស់រួចៗ ដូចជា sedans, jeeps, និង mini vans នៅក្នុងស្តុករបស់យើងៗ ទស្សនាទីតាំងរបស់យើង ដែលនៅជិតអ្នកបំផុត ឬទូរស័ព្ទ វុទ្ធី យក់ សម្រាប់រត់ជួប



Vuthy Yok វុទ្ធី យក់
Sales and Leasing Consultant
Office (978) 746-2500 Ext. 58316
Cell (978) 621-3842
vyok@danobrienautogroup.com




- One Year Maintenance Included
- One Year Paintless Dent Repair
- Free Safety Inspections for you and your entire household
- Lifetime Power-train Warranty

DAN O'BRIEN NISSAN
95 DRUM HILL ROAD,
CHELMSFORD, MA 01824
http://www.DanOBrienNissan.com

DAN O'BRIEN CDJR
175 PELHAM ST,
METHUEN, MA 01844
https://www.danobriencdjr.com

តមកពីទំព័រទី ០១

## ទស្សនៈកិច្ចរបស់ ប៉ាទ្រីក ម័រហ្វី...

ដែលនៅមានទំនាក់ទំនងជាមួយរដ្ឋបាលភ្នំពេញ តាំងតែពីលោកមានដំណែងនៅសាលាក្រុងមកម្ល៉េះ។

លោក ម័រហ្វី និយាយនៅសាកលវិទ្យាល័យ “យូម៉ាសឡូ”ខាងជើងថា ឆ្លៀតពេលដែលរដ្ឋាភិបាលអាមេរិកាំង កោះហៅឯកអគ្គរដ្ឋទូតទាំងអស់ឱ្យវិលត្រឡប់មកប្រជុំនៅរដ្ឋធានី “វ៉ាស៊ីនតោន” លោកក៏យកពេល២ថ្ងៃ មកមើលការរីកចំរើនរបស់ឡូវែល ដែលមានទំនាក់ទំនងដ៏ជិតស្និតជាមួយប្រទេសកម្ពុជា។ លោកបានឱ្យឱវាតនឹងផ្តល់ព័ត៌មានជាច្រើន ដល់យុវជនជានិស្សិតជំនាន់ក្រោយរបស់លោក ដែលបានមកតាំងសំនួរចង់ដឹងពីដំណើរជីវិតរបស់លោក ម័រហ្វី ដែលបាននាំលោកឱ្យមកដល់ឋានៈដ៏ខ្ពង់ខ្ពស់ ក្នុងរដ្ឋាភិបាលអាមេរិកាំង។ “នៅខាំប៉ឹសខាងជើង” នៃបរិវេណមហាវិទ្យាល័យ“យូម៉ាស់ឡូ” លោក ប៉ាទ្រីក ម័រហ្វី បាននិយាយបង្ហាញ ពីនយោបាយនៅកម្ពុជា ដែលលោកបានចូលទៅកាន់ការងារជាឯកអគ្គរដ្ឋទូតតាំងពី៦ខែមកហើយដែរ ឆ្លើយនឹងសំនួរវាគ្មិនខ្លះ ស្តីពីស្ថានភាពនយោបាយនៅកម្ពុជាលោកបានគូសបញ្ជាក់ថា លោកបានឃើញប្រទេសកម្ពុជា កំពុងតែរីកចំរើនមនុស្សរស់នៅយ៉ាងរីករាយរកស៊ីមានបាន... តែលោកបង្ហែមថា កម្ពុជាក៏មានការងារជាច្រើនទៀតត្រូវធ្វើដែរ។

នៅឡូវែលលោកបានទៅពិសារភោជនាហារនៅ“ភោជនីយដ្ឋានភ្នំពេញ”ជាភោជនីយដ្ឋានខ្មែរក្នុងតំបន់ កាលពីថ្ងៃចន្ទនៅផ្លូវ“វ៉ែសហ្វឺត” ដែលប្រាកដជាការផ្តល់កិត្តិយសដល់ម្ហូបអាហារខ្មែរ, បានទៅមើល“ក្រុងខ្មែរ” ដែលជាក្រុងពាណិជ្ជកម្មសុទ្ធតែខ្មែរ, នៅទីនោះ មានតាំងលំអដោយរូបចម្លាក់ខ្មែរក្នុងប្រវត្តិសាស្ត្រខាងធំ ដូចជាមាន“ព្រហ្មបាយ័ន” មានយក្សនិងទេព្តាទាញព្រ័ត“កូរសមុទ្រទឹកដោះ” នៅឯចុងផ្លូវ “ប្រេនស្រ៊ីត” នឹងចុងផ្លូវ“មីឌុលសិច”ប្រជុំមុខគ្នា។ គឺជាកន្លែងដែលខ្មែរគ្រប់រូបមានមោទនភាពនឹងអួតអាងពីតំបន់ ដែលមានអត្តសញ្ញាណជា“ខ្មែរមហានគរ” នឹងគ្រប់គ្រងដោយ សមាគមក្រុងខ្មែរ Cambodia town នោះណាស់។

នៅមានរូបចម្លាក់ខ្មែរមួយទៀតដែរ ដែលតាំងបញ្ឈរនៅមុខបរិវេណសាលាក្រុងឡូវែល ជារូបចម្លាក់ស្តីពីឪខ្មែរភៀសខ្លួន “ឆ្លាក់ដោយសិល្បករ យ៉ារី លីវ៉ាន គឺជាអនុស្សាវរីយនៃប្រជាពលរដ្ឋខ្មែរ បានមកតាំងទីលំនៅដំបូងនៅឡូវែល កាលពី៣០ឆ្នាំមុន ហើយក្រុមប្រឹក្សាក្រុងដឹកនាំដោយលោក រ៉តនីយ អេលីយ៉ុត បានផ្តល់ជីវិតអមតៈដល់ប្រវត្តិកកើតជីវិតថ្មីនៃពលរដ្ឋថ្មីនោះកាលពី៣, ៤ឆ្នាំមុន ។ លោកឯកអគ្គរដ្ឋទូត ម័រហ្វី បានទៅដល់សាលាក្រុងឡូវែល នារសៀលថ្ងៃអង្គារ ដើម្បីទៅទទួលវិញ្ញាប័ត្រសម្តែងការកោតសសើ“ពីសាលាក្រុងតំណាងឱ្យសហគមន៍ខ្មែរ ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះលោកឯកអគ្គរដ្ឋទូត អាមេរិកាំងប្រចាំប្រទេសកម្ពុជា។

# Keep Kids & Teens Busy This Summer with MCC's College for Kids

Caitlin Buckley, MCC Staff Writer

Lowell/Bedford, MA — When the lull of summer hits, Middlesex Community College keeps kids busy and engaged with an array of programming – from LEGO clubs to STEM classes. Registration is now open for MCC's College for Kids 2020 summer programs.

College for Kids offers up to six weeks of programming for full- and half-days for children and teens ages 8 to 17. Programs run July 6 through August 13, on the Bedford and Lowell campuses.

These fun and engaging summer programs provide children and youth with unique opportunities to explore careers, learn new skills, meet new friends and boost self-confidence. Programs are taught by public-school teachers or professionals who are experts in their field.

"College is a scary experience," said Lauren Ellis, MCC's Program Manager of MILES, College for Kids & Personal Enrichment. "But when it is all completed, it is often the best experience those who go through it can have. I like to view the College for Kids program in the same way! College for Kids offers six weeks of endless learning in a fun, hands-on and enriching manner.



"From seeing the Owl Show and holding a chinchilla, to building a city out of Legos or engineering a hovercraft – there is something for everyone. Even better, students get to feel what it is like to be on a college campus where some of the best times of your life take place."

For ages 8-12, kids can take classes in Minecraft, Introduction to Veterinary Science, LEGO Mindstorm Robotics and Battlebots and the Jr. Farmer Program. Classes offered for ages 10-15 include ACE: Aviation, Film Production, All About Science, Engineering Jovercrafts, and LEGO City Planning. For kids 10-15, there is a Zip & Zap Electricity class offered, 12-16 year olds can take Case Studies in Veterinary Medicine, and teens 12-17 can take Medical Laboratory Science.

At MCC's Academic Arts Center in Lowell, performers ages 8 to 17 will stage a production of "James and the Giant Peach, Jr." and performers ages 13 to 17 will put on "Legally Blonde, Jr."

Most full-day classes run 8:30 a.m. to 4:30 p.m. Monday through Thursday. Half-day programs run 8:30 a.m. to noon, and 1 to 4:30 p.m. Students who enroll in two half-day programs can stay on campus for lunch between programs.

For the complete 2020 College for Kids schedule and registration information, visit www.middlesex.mass.edu/collegeforkids/ or call 781-280-3663




***State of Rhode Island***
***Department of Administration***
***Coordinator of Employee Training Programs***

The State of Rhode Island has an opportunity available within the Department of Administration, Division of Human Resources for a Coordinator of Employee Training Programs.

***Coordinator of Employee Training Programs***

Within the Division of Human Resources, the Coordinator of Employee Training Programs serves as the Chief Learning Officer for the Executive Branch of the State of Rhode Island. This position will be responsible for handling all aspects of training programs for the State including, but not limited to, assessing training needs; analyzing such needs and identifying suitable training solutions including the design, customization and scheduling of on-site and e-learning programs; developing curriculum and training materials; preparing course announcements, bulletins, outlines, handbooks, manuals and other materials for use in programs; identifying faculty to deliver the training or, if applicable, delivering the training; coordinating the logistics of all sessions; maintaining evaluations and all training records; and preparing related reports. Additionally, this position serves as the administrator of the State's Learning Management System (LMS) and as such trains system administrators and builders, develops content, manages data transfers and coordinates system expansion. Within this capacity, the Coordinator of Employee Training Programs serves as the point of contact with the LMS vendor and performs other duties as assigned.

**QUALIFICATIONS:**

- Graduation from a college of recognized standing
- Experience – such as may have been gained through employment in a supervisory position involving the development, implementation, delivery and oversight of training programs. The ideal candidate for this position will be a professional Training and Development Manager with related experience leading a Learning and Development function
- Must be able to establish and deliver strategic goals and objectives
- Must have experience with online learning platforms, preferably as the administrator of a Learning Management System (LMS)
- Must possess a strong knowledge of adult instruction and learning theory and principles; instructional design; training methodologies
- Must possess excellent communication and organizational skills and the ability to work independently

***To Apply:***
***Please visit the APPLY RI Website at:*** www.apply.ri.gov

***AN EQUAL OPPORTUNITY EMPLOYER***

# កេ្តិ៍មរតកព្រះតេជគុណ សៅ យន ចេញជារូបរាងនៅវត្តខ្មែរឡូវែល (តពីលេខមុន)

ដោយៈ ពិន សំខុន

លោក សំខាន់ ឃឿន ប្រធានវត្តខ្មែរឡូវែលបានបង្ហាញឯកសារបន្តនិយាយថា គម្រោងក៏សាងវត្តខ្មែរឡូវែល ជាគម្រោងដ៏ធំនឹងដ៏ប្រណិតមួយ ដែលស្ថាប័ត្យករប្រើបច្ចេកទេសស្រូបពន្លឺថ្ងៃ សម្រាប់ចែកចាយពន្លឺក្នុងព្រះវិហ៊ារ ដោយមិនចាំបាច់ប្រើអគ្គីសនី នៅពេលថ្ងៃ, ហើយជាសំណង់នៅខ្ពស់ពីដី នៅលើផ្ទៃដី ១០,០០០ម $^{2}$ (ឬ ៣៣,០០០SF)មិនរំខានផ្លូវទឹកដោយសារតែជាតំបន់ដីទំនាបលិចទឹកនោះទេ។

សំណង់ប្រកបដោយមហិច្ឆិតារបស់ព្រះអង្គ សៅ យន ពេលនៅមានព្រះជន្មចង់បានវត្តអារាមថ្មីមួយ ដ៏ល្អលើសគេ នឹងប្រើថវិការចំនួន១៧លានដុល្លារ ដើម្បីសានសង់ ដែលមិនមែនត្រឹមតែជាវត្តព្រះពុទ្ធសាសនាខ្មែរតែប៉ុណ្ណោះទេ តែក៏ជា"មជ្ឈមណ្ឌល វប្បធមិខ្មែរ"ដែរ ដែលក្នុងវត្តនោះ នឹងមានទីតាំងបណ្ណាល័យមានសាលបាលី មានសារមន្ទីរសម្រាប់តាំងពីប្រវត្តិប្រទេសកម្ពុជា មានសាលារៀន អក្សរសាស្ត្រ មានកន្លែងធ្វើវិបស្សនា... ប្រកបដោយទីធ្លា សួនច្បារ នៅជុំវិញបរិវេណព្រះវិហារ ចំណតរថយន្តដ៏ធំទូលាយ ដែលនឹងធ្វើឱ្យមជ្ឈមណ្ឌលខ្មែរនោះ នឹងក្លាយ ទៅជារមនីយដ្ឋានមួយដ៏គួរឱ្យចង់ចូលកំសាន្តសំរាកកាយផង។


អ្នកស្រី ម៉ាយ៉ាមែន បង្ហាញគម្រោងសង់វត្ត


បន្ទប់រក្សាសពព្រះតេជគុណ សៅ យន

លោក សំខាន់ ឃឿន ដែលបានចូលរួមរៀបគម្រោងសង់វត្តដ៏ធំអស្ចារ្យនេះ អស់រយៈពេលច្រើនឆ្នាំមកហើយ ជាមួយអតីតព្រះអង្គចៅអធិការ សៅ យន, នឹងជាមួយអ្នកស្រី ម៉ាយ៉ាមែន បច្ចុប្បន្នជាអនុប្រធានវត, លោកជាសាស្ត្រាចារ្យ នឹងជាអតីតប្រធានសមាគមខ្មែរធ្លាប់គ្រប់គ្រងថវិការច្រើនលានដុល្លាបានច្រើនឆ្នាំ, ដូចនេះបានបង្ហាញបទពិសោធន៏ក្នុងការរកថវិការសម្រាប់សំណង់វត្តខ្មែរឡូវែលនេះជាថ្មីម្តងទៀត។ ការរកថវិការឱ្យបាន១៧លាននេះ លោករំពឹងទៅលើទី១ ជំនឿសាសនារបស់ពុទ្ធបរិស័ទ ដោយសុំឱ្យពុទ្ធបរិស័ទជួយជាវរូបចម្លាក់ព្រះពុទ្ធបដិមាករចំនួន៨៤,០០០អង្គ ដែលជាលេខដំណាងឱ្យធម្មក្ខ័ន្ធព្រះពុទ្ធសាសនា, ទី២ ស្នើសុំជំនួយឧបត្ថម្ភពីអង្គការរដ្ឋ ដើម្បីកសាងមជ្ឈមណ្ឌលវប្បធមិក្នុងនាមនៃកម្មវិធីសមាគមមិនយកប្រាក់កម្រៃ, ទី៣ រកដៃគូរអភិវឌ្ឍន៏ក្នុងនឹងក្រៅតំបន់ គឺអង្គការដែលគេត្រូវការពង្រីកសមត្ថភាពរបស់គេចូលមកដល់សហគមន៏ខ្មែរ។ ជាការពិតណាស់ដែលសហគមន៏ខ្មែរ ត្រូវការជំនួយដ៏ច្រើនទៀត តាមរយៈជំនឿសាសនាសម្រាប់អភិវឌ្ឍន៏សេដ្ឋកិច្ចនឹងបញ្ញាមនុស្ស ដោយសារខ្មែរយើងជាប្រជាពលរដ្ឋថ្មីមិនទាន់មានវប្បធមិ, ជំនាញ នឹងចំណេះ គ្រប់គ្រាន់ជាសហគមន៏ជឿនលឿននឹងគេនៅឡើយទេ។

កាលពីលេខមុនយើងបាននិយាយថា ព្រះអង្គ សៅ យន ធ្លាប់ជាប្រធានសហគមន៏ព្រះសង្ឃខ្មែរលោកចូលទីវង្គត់ ដោយបន្សល់ទុកសហគមន៏ព្រះសង្ឃ ដែលមិនមានសកម្មភាពថ្មីឡើយ **តទៅទំព័រទី១១**






តមកពីទំព័រទី ១០

## កេរ្តិ៍មរតកព្រះតេជគុណ សៅ យន...

បើទោះជាគណកម្មការបន្តវេននោះ នៅ-មានវត្តមាននៅឡើយក្តី ។



រូបសំណាកព្រះពុទ្ធបដិមាករដាក់សម្រាប់ពុទ្ធបរិស័ទជាវ

ព្រះតេជគុណ ធន់ សុផន ជាប្រធានបន្តវេន គង់នៅវត្តលីន មិនទាន់មានគម្រោងបន្តដំណើរសហគមន៍ព្រះសង្ឃនោះទេ បើទោះជាសហគមន៍នោះជាម្ចាស់ដីនៃវត្តខ្មែរក៏ដោយ ប៉ុន្តែលោកសំខាន់ឃើនទុកឱកាសនឹងទីកន្លែងឱ្យសហគមន៍ព្រះសង្ឃខ្មែរ បន្តសកម្មភាព នៅទីវត្តខ្មែរឡូវែលបានដដែល ។ នៅពេលជាមួយគ្នានោះ នៅឯ“រដ្ឋមេនីសូតា”ឯណោះ ក៏មានកំណើត“ពុទ្ធិកសមាគម ព្រះសង្ឃ” មួយទៀត ដែលរួមប្រជុំដោយវត្តខ្មែរជាច្រើនដូចគ្នា ក្នុងបំណងលើកស្ទួយព្រះពុទ្ធសាសនាថេរវាទ ឱ្យទទួលបាននូវការលើកដំកើង ។ អង្គការទាំង២នេះ អាចនឹងមានប្រយោជន៍ណាស់សម្រាប់ភាពចុះសម្រុងគ្នាតាមវត្តនិមួយៗ ដែលនៅក្រោមចំណុះ ប៉ុន្តែវត្តអារាមខ្មែរនៅអាមេរិកកំពុងនៅឆ្ងាយពីការពិតនៅឡើយ ទីវត្តអារាមសម្បូរដោយជម្លោះ ក្នុងវត្តក៏មានក្រៅវត្តក៏មានទំនងជាមានតែអង្គប្រជុំជាន់ខ្ពស់នៃព្រះសង្ឃទេ ទើបអាចរកដំណោះស្រាយដោយច្បាប់នឹងដោយវិន័យតាមផ្លូវសាសនាឃើញ ។



គម្រោងសង់វត្តខ្មែរឡូវែល មានទំហំធំស្រស់ស្អាតខ្លាំងណាស់ តែមិនទាន់ធានាថា នឹងគេចផុតពីទំនាស់ ដូចវត្តដ៏ទៃឯទៀត ដោយគ្មានច្បាប់នឹងវិន័យសម្រាប់គ្រប់គ្រងបុគ្គលិក ដែលបំរើការក្នុងវត្តគ្រប់គ្រាន់នៅឡើយ ។ ព្រះសង្ឃអាចារ្យវត្ត យាយជីតាជី សុទ្ធសឹងតែបំរើវត្តពេញពេលដោយស្ម័គ្រចិត្ត ប៉ុន្តែពុំអាចមានការទទួលខុសត្រូវតាមច្បាប់ ឬតាមវិន័យក្រឹត្យក្រម ដែលអាចពិន័យអ្វីបានឡើយ, ដែលជាហេតុនាំឱ្យងាយស្រួលនឹងឃ្លាតចាកភាពបរិសុទ្ធ នឹងធ្វើឱ្យអនាគតនៃវត្តខ្មែររួញខើចដោយក្មេងៗជំនាន់ក្រោយ លែងមានជំនឿ សាសនាព្រះពុទ្ធ ដូចឪពុកម្តាយខ្លួនឡើយ ។

ក្នុងឱកាសដែលវត្តទើបនឹងកើតថ្មីវត្តខ្មែរឡូវែល ក្រោមការដឹកនៃសតិបញ្ញាដោយព្រះគ្រូចៅអធិការ ហែម សុភណ្ឌ គួរតែធ្វើការកែទម្រង់ដ៏ជ្រាលជ្រៅមួយទុកជាគំរូដល់កុលបុត្រកុលធិតា ជំនាន់ក្រោយឱ្យមានសមាណចិត្តចង់ទ្រទ្រង់អំពើបុណ្យការពារព្រះពុទ្ធសាសនាឱ្យបន្តស្រឡាញ់ភាពបរិសុទ្ធ មានជំនឿលើការស្រឡាញ់រាប់អាន ជួយយកអាសារគ្នាទៅវិញទៅមក, ទាំងអស់នោះ ត្រូវអនុវត្តន៏តាមជំនាញជាវិជ្ជាជីវ មិនអាចធ្វើស្មានបានឡើយ ។

តមកពីទំព័រទី ១២

## ជូនកាលក៏មានប្រយោជន៍គួរអោយជឿ..

បេក្ខជននោះ នៅខ្វះឆ្នោត៣០០សន្លឹក ទើបជាប់... ទើបគេជេពួកតុកាហ្វេយ៉ាងចាស់ដៃ ហើយបង្អាប់ថា “ពួកនោះ ជាពួកគាំទ្របក្សប្រជាជន”,... ពេលនោះទើបគេដឹងថា ក្រុមលេងសើចនៅតុកាហ្វេនោះ មានគ្នាដល់ទៅ៣០០នាក់ផង! ដូច្នេះលេង១ចាននេះ មើលងាយថា “គ្មានសម្បជញ្ញៈ”មិនបានទេណា ។

តាមពិតទៅក្រុមតុកាហ្វេរីករាយបានបង្កើតបរិយាកាសងាយស្រួលសម្រាប់អាយុវែងគ្មានកង្វល់ស្មុកស្មាញបាតដៃស្អាតគ្មានពុករលួយចេះជួយខ្លួនឯង នឹងជួយដល់ពលរដ្ឋកម្ពុជានឹងជួយតម្រង់ផ្លូវដល់អ្នកដែលវង្វេងដោយមានជនបញ្ឆោត...ជួយជាអ្នកគាំទ្រពុទ្ធសាសនាដល់សិក្សាធិការដល់ស្មារតីរៀបចំក្រុងដែលខ្លួនឯងរស់នៅនឹងគាំទ្រដល់ប្រទេសអាមេរិកផង ។ គេលេងសើចជារៀងរាល់ព្រឹកមែនតែគ្មានប្រកាន់ខឹងប្រយោគមិនអាចយកជាការបានទាំងអស់ទេ តែបានបង្រៀនយើងទាំងអស់គ្នាពីជីវិតដោយមិនដឹងខ្លួន ។


ធ្វើយ៉ាងនេះបានប្រពន្ធខ្លាច


ធ្វើមិនដូចទេ!!

មានអ្នកមកដល់សហរដ្ឋអាមេរិកថ្មីៗកាន់តែច្រើនគ្រួសារបានមកចូលរួមរំលែកសំណើចនឹងទឹកភ្នែកជាមួយតុកាហ្វេរីករាយបានធ្វើឱ្យជីវិតថ្មីថ្មោងនៅដែនដីថ្មីរបស់ពួកគេក្លាយទៅជាអភិវឌ្ឍន៍យ៉ាងងាយស្រួលនឹងឆាប់រហ័ស ។ តុកាហ្វេរីករាយនាហាងគុយទាវភ្នំពេញ ក៏បានក្លាយទៅជាមណ្ឌលសង្គមកិច្ចក្រៅផ្លូវការមួយដ៏មានប្រសិទ្ធិភាពដែល គេរកអ្វីក៏បានរកអ្វីក៏ឃើញទាំងអស់គ្នាជាអ្នកផ្តល់ព័ត៌មានចាំបាច់ជួយណែនាំជាបុគ្គលិកស្មោះស្ម័គ្រចិត្ត ហើយដែលជួយគ្នាដោយគ្មានប្រកាន់ នឹងដោយទឹកមុខញញឹម ។



សម្លេងតុកាហ្វេ

# “ជួនកាលក៏មានប្រយោជន៍គួរអោយជឿបានដែរ”

ដោយ ពិន សំខុន

នៅតុកាហ្វេនាហាងគុយទាវ"ភ្នំពេញ" វេលារៀងរាល់ម៉ោង៨ព្រឹកនៅឡូវែល តែងមានចាស់ទុំ នឹងមេគ្រួសារប្រមាណ១០, ២០ នាក់ ច្រើនតែប្រុសៗរកគ្នាដើម្បីជួបជុំជជែកពីនេះពីនោះ បំបាត់ការអផ្សុក កែរតប់ប្រមល់ពេលនៅផ្ទះ ដោយគ្មានការងារធ្វើ ហើយយកមកជះកង្វល់ទាំងនោះ នៅទីប្រជុំតុកាហ្វេ យ៉ាងមានប្រសិទ្ធិភាព។ ជាទូទៅ រឹទ្ធី សៅ មន្ត្រីធ្វើតាក់ តែងមកដល់មុនគេ បន្ទាប់ពីយកកូនតូចទៅដាក់នៅសាលារៀនរួច, តែអ៊ីឡូវល្បែងសៀង គ្រូជំនាញអាំងជ្រូកខ្វៃ បានកាត់មុខជាអ្នកមកអង្គុយចាំមុនគេទៅវិញ្ញ រួចហើយក៏មាន ចក្រី ឯម "ជាមេទ័ព"កាលពីមុន អ្នកប៊ុងដឹងរឿងគ្រប់យ៉ាងគ្មាននរណានិយាយកាត់បានឡើយ, នៅមានទៀត "តាសារឿនប្រពន្ធក្មេង" មិនចូលចិត្តល្បែងទេ តែឆ្នោតមិនទាន់កោស នៅពេញហោប៉ៅរាល់ព្រឹកមិនដែលដាច់, នឹងម្នាក់ទៀត "បងសារឿនប្រពន្ធចាស់"ជាអាចារ្យវត្ត ក៏មិនទៅណាចោល"តុកាហ្វេរីករាយ"នោះដែរ គាត់ពូកែទាយព្រឹត្តិការនយោបាយមិនអន់ទេ។

ចាស់ៗដែលមិនចង់ជរាឆាប់ តែងតែមកប្រវ៉ាស់សម្តីដាក់ទុននៅប្រពន្ធ" នៅពេលម្នាក់



នាំគ្នាកោសឆ្នោតចិញ្ចឹមមេ

នោះទទួលទូរស័ព្ទម្តងៗ,"អុំស្រី"ដែលជាឈ្មោះដាក់ឱ្យល្បួង ហ៊ុំ ត្រកូល ហ៊ុន តែងតែចេញមុខមកបង្រៀនសមាជិកតុកាហ្វេរីករាយ ពី"វិធីបំបាក់ស្មារតីប្រពន្ធ"វិញ... ដោយផ្តើមពីការបង្ហាញមុខក្រញូវ ហើយគ្រហឹមត្រឹមតែធ្វើ"ហ៊ឺស!", ទៅណាស្រេចតែអញ! "ដាក់ប្រពន្ធ រួចក៏ដើរចេញពីផ្ទះ ទាំងក្រញូវនោះទៅ!។ បង្រៀនរួចហើយ ស្រាប់តែទូរស័ព្ទ"អុំស្រី"ក៏រោទិ៍ឡើង, "អុំស្រី"ក៏លើកទូរស័ព្ទយ៉ាងប្រញាប់ប្រញាល់ហើយនិយាយថា "...បងនឹងប្រញាប់ទៅវិញ ចាំបងទិញបបរផ្ញើរណា..." ដែលប្រយោគនោះធ្វើឱ្យគេសើចគិលឡើង...។

ថ្ងៃសៅរ៍នេះ មានមនុស្សមកតុកាហ្វេចំនួនតិច ពីព្រោះត្រូវជូនគ្រួសារ ទៅទិញអង្ករ ទិញទឹកផឹក ទិញម្ហូបក្រៀម ទុកបង្កាឱ្យអស់ពីហាង ពីព្រោះគេខ្លាចជម្ងឺកូរ៉ូណា មកដល់អាមេរិក, អ្នកលក់ម្នាក់ប្រាប់ថា អាចនឹងគ្មានកុប៉ាល់ដឹកអង្ករពីអាស៊ី មកលក់នៅអាមេរិក ដូច្នេះទុរភិក្សនឹងកើតមានឡើង... ល្បួងសៀងថា "មិនជឿថានៅអាមេរិកឯណា នឹងគ្មានអង្ករលក់នោះទេ", តែល្បួងសារឹទ្ធ បន្តថា "តែម៉ែវាប្រាប់ឱ្យទៅទិញអង្ករទុកដាក់រួចទៅហើយ..."។



អ្នកកោសឆ្នោតចិញ្ចឹមឆ្នាំង

គេនិយាយទឹកដល់កាលពីឆ្នាំមុន មានបេក្ខជនតំណាងរាស្ត្រម្នាក់ ចូលតុកាហ្វេច្រឡំវង្ស បានសុំអញ្ជើញសមាជិកតុកាហ្វេរីករាយឱ្យជួយបោះឆ្នោតឱ្យគេ ក្នុងនាមជា"ខ្មែរដូចគ្នា" គ្មាននរណាប្រកែកនឹងសំណើរនេះទេ, តែដល់ចេញលទ្ធផលមក **តទៅទំព័រទី១១**


## ជួយរក្សាកូនរបស់យើងអោយមានសុវត្ថិភាព ពីការប្រើប្រាស់ថ្នាំពេទ្យខុស



### លោកអ្នកអាចជួយបាន៖ដាក់ថ្នាំអោយឆ្ងាយពីដៃ

- ទុកដាក់ថ្នាំពេទ្យនៅកន្លែងចាក់សោបិទជិត
- ឧស្សាហ៍រាប់ចំនួនគ្រាប់ថ្នាំនៅក្នុងដបនីមួយៗ

សុំឪពុកម្តាយមិត្តភក្តិរបស់កូនអ្នកអោយការពារថ្នាំពេទ្យរបស់ពួកគេផងដែល

### អ្នកអាចជួយបានច្រើនជាងនេះ

- ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីវិធីដើម្បីគ្រប់គ្រងការឈឺចាប់របស់អ្នក
- សួរអ្នកលក់ថ្នាំរបស់អ្នកអំពីច្បាប់បំពេញដោយផ្នែកៗ

(Partial-Fill Law), ដែលអនុញ្ញាតអោយអ្នកសុំថ្នាំមានជាតិអាភៀនកំរិតទាប។

### ចោលថ្នាំពេទ្យ

- យកថ្នាំទៅទំលាក់ចោលនៅបុស្តិ៍ប៉ូលីសនាទីក្រុងឡូវែល (City of Lowell Police Department's Drop-off kiosk) (មិនមានអ្នកណាសួរសំណួរអ្វីឡើយ)
- បោះចោលថ្នាំពេទ្យដែលលែងត្រូវការនិងម្ជុលចាក់ នៅថ្ងៃដែលត្រូវកំណត់អោយបោះចោលរបស់ទីក្រុងឡូវែល។

ការយកថ្នាំដែលអ្នកលែងត្រូវការចោលបានន័យថា អ្នកបានជួយរក្សាគ្រួសាររបស់អ្នក និងសហគមន៍របស់យើងកុំអោយមានគ្រោះថ្នាក់!

March 10, 2020
ថ្ងៃទី១០ ខែមិនា ឆ្នាំ២០២០
2:00 រសៀល - 6:00 ល្ងាច
ក្រសួងសុខាភិបាលនៃទីក្រុងឡូវែល
341 Pine Street, Lowell ឥតគិតថ្លៃ

ថ្ងៃទទួលថ្នាំ និងម្ជុលដែលលែងត្រូវការ

យើងទទួល៖
- ថ្នាំដែលជាបញ្ញត្តិគ្រូពេទ្យ
- ថ្នាំពេទ្យ ទិញដោយមិនបាច់មានបញ្ញត្តិពេទ្យ
- ថ្នាំទឹក
- ថ្នាំបំពង់ហឺត
- ស្ពាំងចាក់ថ្នាំ
- ប៊ិច ម្ជុលជួសម្រាមដៃសម្រាប់មើលជាតិស្ករ
- ថ្នាំបំពង់បន្សាបគ្រឿងញៀនណាវខែន

ទាក់ទងលេខ 978-674-4304 ឬ គេហទំព័រ www.lowellma.gov ដើម្បីព័ត៌មានបន្ថែម។
សំរាប់អ្នកដែលរស់នៅតាមផ្ទះបោះបោល -ពុំមែនសំរាប់ក្រុមហ៊ុនពាណិជ្ជកម្មទេ

Lowell Health Department
Prevent • Promote • Protect

# DEPORTATION: DEFENSES FOR PEOPLE WITH FINAL ORDERS OF REMOVAL



My focus in this series has been defenses for people with Final Orders of Removal and I have already covered the two most productive reasons for reopening these cases. One is the recent issue of whether the crime for which they had been ordered deported really is a deportable offense under current case law. There have been a number of First Circuit and even Supreme Court decisions stating that crimes that were once thought to be crimes of violence and thus potential aggravated felonies, are not. The other is the so-called "Padilla Motion", in which the underlying criminal conviction is vacated because the criminal defense lawyer failed to advise an Alien Defendant properly concerning the immigration consequences of the plea or even of rejecting a plea and going to trial. Neither of these defenses required that the underlying crime be an aggravated felony. I recently won a case in Immigration Court where the drug possession charges were vacated because of corruption in the state crime lab. I once had a simple weapons possession charge, which is not an aggravated felony but nevertheless grounds for deportation, dismissed on Padilla grounds.

Beyond these two methods, things get a little trickier, especially for people who have Final Orders of Removal. There are two other methods, which can be effective but are largely much based on luck. The first of these is very similar to the Padilla issues I discussed in my second article. However, this involves the judge not issuing a proper warning. M.G.L. Chapter 278, Section 29D, mandates that anytime someone pleads guilty or admits to sufficient facts or otherwise takes a plea in a criminal case, the judge issue the following immigration warning:

"If you are not a citizen of the United States, you are hereby advised that the acceptance by this court of your plea of guilty, plea of nolo contendere, or admission to sufficient facts may have consequences of deportation, exclusion from admission to the United States, or denial of naturalization, pursuant to the laws of the United States." The court shall give this warning during every plea colloquy."

Unlike with the Padilla motion, if the judge did not give a proper immigration warning, "prejudice" does not need to be proved. Put another way, even if the Criminal Defendant has been fully apprised of the immigration consequences of the case by the Attorney, and is fully aware of the deportation risk and, of course, has signed a written immigration warning also containing these words, the plea is vacated and the case is reopened.

More importantly, the Massachusetts Supreme Judicial Court (SJC) has recently shown less tolerance for judges deviating from the script provided by the legislature. There is a series of cases in which the SJC acknowledged that the judge did not give a proper warning but managed to find a way to uphold the conviction anyway. In its most recent decision however, it has declared its interpretation of the statute to be "strict" and although they did not quite mandate that the judge read the warning word-for-word, they have essentially indicated that that is what they want judges to do. I will be testing this decision soon. I have a case in which the judge, in the course of his warning, managed to get every word of the statute out but interspersed it with a lot of other words which made the warning confusing and actually undercut the legislative purpose. When I first started researching this issue, I thought that I was creating an issue for appeal. In view of the recent SJC decision though, I think I have a strong issue for the trial court itself.

The problem though is that it requires the judge not give a proper immigration warning. Some judges have a tendency simply to read the warning as written in every single case, in large part because they have no interest in what the Defendant's circumstance may be and simply want to get it over with. Ironically, a mumbled pro forma but literally compliant warning is unlikely ever to be overturned. It is when the judges start taking an interest and tailoring a warning to a specific case that they are at risk

**Please read page 15**

## សេចក្តីជូនដំណឹងស្តីពី ការរៀបចំកិច្ចប្រជុំជាសាធារណៈ និងឱកាស ក្នុងការផ្តល់មតិយោបល់ នៅលើពង្រៀង វិសោធនកម្មគម្រោង កម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ២០២០-២០២៤ របស់ អង្គភាព រៀបចំក្រុង ន័សធន មុីដូលសិច

អង្គភាពរៀបចំក្រុង ន័សធន មុីដូលសិច (Northern Middlesex Metropolitan Planning Organization) ហៅកាត់ NMMPO បាន ប្រកាសផ្សព្វផ្សាយដើម្បីឱ្យសាធារណៈជនធ្វើការផ្តល់ជាមត្តិយោបាលទៅលើពង្រៀងវិសោធនកម្មចំពោះគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ ២០២០-២០២៤ ។ សំណើរពង្រៀងវិសោធនកម្មនេះមានរួមបញ្ចូលទាំងថវិការការរៀបចំផែនការសម្រាប់គម្រោងពង្រីកMerrimack Riverwalk នៅក្នុងក្រុងឡូផងដែរ ។

លោកអ្នកអាចចូលអានសេចក្តីសង្ខេបនៅការធ្វើវិសោធនកម្មនេះតាមរយៈនៅវ៊ិបសាយ www.nmcog.org ។

មានកិច្ចប្រជុំពីរដែលបានរៀបចំឡើងកាលពីពេលថ្មីៗនេះ ។ ទីមួយ កិច្ចប្រជុំជាសាធារណៈដើម្បីទទួលយកនូវមតិយោបល់ពីសាធារណៈជនទៅលើពង្រៀងវិសោធនកម្ម ដែលនឹងប្រព្រឹត្តទៅនៅម៉ោង៥:៣០ ល្ងាច ខែមិនា នៅទីតាំងការិយាល័យក្រុមប្រឹក្សាភិបាល ន័សធន មុីដូលសិច ( Northern Middlesex Council of Governments) ដែលមានអាស័យដ្ឋាន 40 Church Street, Suite 200 ក្រុងឡូវ៉ើល រដ្ឋម៉ាសាជូសេដ ។ លោកអ្នកក៏អាចផ្តល់ជាមតិយោបល់តាមរយៈទូរស័ព្ទដោយខលទៅកាន់លេខ (978) 454-8021, ext. 121 រឺតាមរយៈអុីម៉េល jhoward@nmcog.org ។ ប្រសិនបើចង់សរសេរជាលិខិត លោកអ្នកអាចផ្ញើរទៅកាន់អាស័យដ្ឋានខាងលើបាន ។ ពេលវេលានៃការផ្តល់មតិយោបលជាសាធារណៈសម្រាប់វិសោធនកម្មគម្រោង TIP នេះ នឹងត្រូវបញ្ចប់នៅថ្ងៃទី ២០ ខែមិនា ។ កិច្ចប្រជុំជាសាធារណៈទីពីរនឹងរៀបចំឡើងនៅម៉ោង ២:00 រសៀល ថ្ងៃទី២៥ ខែមិនា នៅការិយាល័យ NMMPO នៅពេលដែលដំណើរការនៃការចូលរួមជាសាធារណៈរបស់អង្គភាព NMMPO ស្របទៅនឹងតំរូវការនៃការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន ។

**កំណត់ចំណាំ:** ទីកតាំងនៃការរៀបចំកិច្ចប្រជុំនេះ ងាយស្រួលសម្រាប់ឱ្យជនពិការចេញចូល និងនៅជិត និងចំណតឡានក្រុង ។ អង្គភាព NMMPO មានទីតាំងសុវត្ថិភាពសម្រាប់ចំណតកង់ ដែលស្ថិតនៅជាន់ទី ២ ។NMMPO ក៏ផ្តល់ផងដែរនូវទីន្លែងស្នាក់នៅដ៏សមរម្យ និង,រឺ ជំនួយផ្នែកភាសាដោយមិនគិតថ្លៃ ប្រសិនបើមានការស្នើរសុំ (មានដូចជាអ្នកបកប្រែជាភាសាអង់គ្លេស និងភាសាផ្សេងទៀត, បកប្រែភាសាដោយមើលរឺស្តាប់តាមរយៈវីដេអូសម្រាប់អ្នកពិការភ្នែក និងថ្លង់, ឧបករណ៏បកប្រែជាសម្លេងសម្រាប់អ្នកគរថ្លង់ និងជនពិការភ្នែក ព្រមទាំងការចែកជូនឯកសារផ្សេងទៀត) តាមដែលមាន ។សម្រាប់ការចូលរួមរបស់លោកអ្នក និងជំនួយបន្ថែម សូមទំនាក់ទំនងលោក Justin Howard តាមរយៈលេខទូរស័ព្ទ (978) 454-8021, ext 121 រឺអុីម៉េលទៅកាន់ jhoward@nmcog.org ។ រាល់ការស្នើរសុំជំនួយនានា ដូចជាភាសាកាយវិកា, ការបកប្រែផ្ទាល់ៗ រឺការបកប្រែភាសា សូមទំនាក់ទំនងមកយើងខ្ញុំឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីងាយស្រួលក្នុងការរៀបចំ ។

## NOTICE OF PUBLIC MEETINGS AND COMMENT OPPORTUNITY: Draft Amendment to the NMMPO's FFY 2020-2024 Transportation Improvement Program

The Northern Middlesex Metropolitan Planning Organization (NMMPO) has released for public comment a draft amendment to the FFY 2020-2024 Transportation Improvement Program (TIP).The proposed TIP amendment involves programming funds for the Merrimack Riverwalk Extension Project in Lowell. A summary of the amendment can be found at www.nmcog.org.

There are two public meetings currently scheduled. One, a public meeting to receive comments on the draft amendment will be held on March 10, 5:30 PM, at the Northern Middlesex Council of Governments (NMCOG) offices, 40 Church Street, Suite 200, Lowell, MA. You may also submit comments by phone at (978) 454-8021, ext. 121, or by email: jhoward@nmcog.org. If preferred, comments may be mailed to the above address. The public comment period for the TIP amendment ends on March 20. The second public meeting is scheduled for March 25, 2:00 PM at NMCOG offices, when the NMMPO will meet to consider endorsement of the amendment. The NMMPO's public participation process satisfies the LRTA's public participation requirements for the program of projects.

**Notice:** This meeting location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext. 121 or at jhoward@nmcog.org. Requests should be made as soon as possible for services requiring advanced arrangements, including sign language, CART or language translation or interpretation.

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare

### Home Care Agency

Group Adults Foster Care Program

***ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។***

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មាសហ៊ែលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# DEPORTATION: DEFENSES

/ From Page 13

of getting reversed. The only way to know if a judge gave a proper warning is to have the plea colloquy transcribed. The good news is that if the plea colloquy no longer exists, the court is not entitled to a presumption that it gave a proper warning. The bad news is that an affidavit from the judge

saying "I always give a proper warning" is usually going to be accepted as proof that a proper warning was given.

Another luck of the draw kind of situation is when the parent of the person who has been ordered deported has been naturalized before that person's eighteenth birthday. I have had a few people come to me because they tried to naturalize and were told at their naturalization interviews that they were already US Citizens because their parents had naturalized before they turned eighteen. One of the interesting problems that we encounter is that you must prove that such a person is a US Citizen and it fell upon me to take care of that. However, this can be an issue in the deportation context as well. If you were living with your parents and it was the day before your eighteenth birthday when a parent with whom you lived took the oath of citizenship and became a United States Citizen, you are a United States Citizen. If you are a Citizen, you cannot be deported, and that Final Order of Removal needs to be vacated. In fact, I would go so far as to say that, notwithstanding the existence of a Final Order of Removal, you are entitled to go to the US Embassy, get a US passport, and come home. However, proving that you were in the physical custody of your naturalized parent at that time, where that time was probably a long time ago, can be a challenging, but hardly impossible, issue. Unfortunately, the mere fact that the parent naturalized does not mean that you naturalized. There are other conditions as well. Still, this can be a fool-proof method of beating deportation, even where a Final Order of Removal has already entered.










**PRINT READERSHIP**
*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2020 PRINTING SCHEDULES

## EFFECTIVE FEBRUARY 1, 2020

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue<br>5% Savings | 3 Months (6 Issues)<br>7.5% Savings | 6 Months (12 Issues)<br>10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| **Full** (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| **1/8** (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

**Your ad is also published in our online editions of the newspaper at khmerpostusa.com**




## MONTHLY DISTRIBUTION

***70+ Locations in Lowell, MA • 7,000 copies***
***25 Locations in Lynn & Revere, MA • 1,000 copies***
***25 Locations in Providence & Cranston, RI • 2,000 copies***
***Additional distribution online***

### *Khmer Post USA Distribution Locations Include:*

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

***Advertising deadlines are 5 business days prior to printing date.***

## CONTACT INFO

**27 Jackson Street • Unit 329 • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

Follow us @KhmerPostUSA

Follow us @KhmerPostUSA